ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលនៃការចូលរួមកិច្ចពិភាក្សាទូទៅក្នុងសម័យប្រជុំលើកទី៧៤ នៃមហាសន្និបាត អង្គការសហប្រជាជាតិ (អ.ស.ប) និងកិច្ចប្រជុំពាក់ព័ន្ធ ថ្ងៃទី ២៣-២៨ ខែកញ្ញា ឆ្នាំ២០១៩ ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក

-------------------

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចពិភាក្សាទូទៅក្នុងសម័យប្រជុំលើកទី៧៤ នៃមហាសន្និបាតអ.ស.ប ក្រោមមូលបទ៖ "ជំរុញកិច្ចប្រឹងប្រែងពហុភាគី សម្រាប់ការលុបបំបាត់ភាពក្រីក្រ ការអប់រំប្រកបដោយគុណភាព សកម្មភាពអាកាសធាតុ និងបរិយាប័ន្ន" និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ២៣ដល់ថ្ងៃ ២៨ ខែ កញ្ញា ឆ្នាំ ២០១៩ នាទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

<u>កិច្ចពិភាក្សាទូទៅក្នុងសម័យប្រជុំលើកទី៧៤ នៃមហាសន្និបាតអ.ស.ប</u>

ថ្លែងនាថ្ងៃទី ២៨ ខែ កញ្ញា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកឡើងអំពីតថភាពនៃពិភពលោកពហុប៉ូល និងភាពផុយស្រួយនៃពហុភាគីនិយម ដោយសារកិច្ចគាំពារនិយម និងឯកតោភាគីនិយម និងការបន្តជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ដោយបំពានលើធម្មនុញ្ញរបស់ អ.ស.ប ។ ការជ្រៀតជ្រែកគ្រប់រូបភាពនៅបន្តកើតមានឡើង ហើយព័ត៌មានក្លែងក្លាយបានក្លាយទៅជាអំណះអំណាងនៃការជ្រៀតជ្រែកផង និងជាឧបករណ៍នៃនយោបាយអន្តរជាតិផង។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា ការគោរពគោលការណ៍សមភាព និងអធិបតេយ្យភាព ការគោរពសិទ្ធិក្នុងការចាត់ចែងជោគវាសនាដោយខ្លួនឯង និងគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ដូចមានចែងក្នុងធម្មនុញ្ញ អ.ស.ប មានសារៈសំខាន់ចាំបាច់ក្នុងការធានាឱ្យពហុភាគីនិយមរស់រានបន្ត និងអាចស្វែងរកនូវមាគ៌ាសន្តិភាព និងស្ថិរភាព សាមគ្គីភាព និងវឌ្ឍនភាព។



អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនអង្គមហាសន្និបាតអំពីបច្ចុប្បន្នភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា ដែលផ្តោតជាសំខាន់លើគុណភាព និងបរិយាប័ន្ននៃការអភិវឌ្ឍឈរលើស្មារតី "មិនទុកនរណាម្នាក់ចោលឡើយ" ការចូលរួមចំណែករបស់កម្ពុជាក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់ អ.ស.ប និងបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការបន្តគាំទ្រលើពហុភាគីនិយម ពាណិជ្ជកម្មសេរី និងសណ្តាប់ធ្នាប់អន្តរជាតិដែលផ្អែកលើវិធានច្បាប់ និងមាន អ.ស.ប ជាស្នូល។

<u>កិច្ចប្រជុំក្រៅផ្លូវការរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនៃរដ្ឋសមាជិកនៃសន្និសីទស្តីពីអន្តរសកម្មភាពនិងការកសាងទំនុកចិត្តនៅអាស៊ី (CICA) (ថ្ងៃទី២៣ ខែកញ្ញា)៖</u>

បន្ទាប់ពីស្តាប់លទ្ធផលនៃកិច្ចប្រជុំកំពូល CICA លើកទី៥ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ កន្លងទៅ នៅទីក្រុង Dushanbe កិច្ចប្រជុំក៏បានពិភាក្សាអំពីផែនការការងាររបស់ CICA ឆ្នាំ២០២០ សម្រាប់រយៈពេល ៤ ឆ្នាំបន្ទាប់ ផ្តោតលើការងារអាទិភាព ៤ គឺ៖ ១) កិច្ចប្រជុំ CICA ២) ការអនុវត្តវិធានការកសាងទំនុកចិត្ត (លើទិដ្ឋភាពយោធា-នយោបាយ ការគំរាមកំហែងនិងបញ្ហាប្រឈមថ្មី សេដ្ឋកិច្ច បរិស្ថាន និងមនុស្ស) ៣) ទំនាក់ទំនងខាងក្រៅ និង៤) ព្រឹត្តិការណ៍របស់លេខាធិការដ្ឋាន។

<u>កិច្ចប្រជុំកម្រិតខ្ពស់ស្តីពីការធានារ៉ាប់រងសុខភាពជាសកល (ថ្ងៃទី២៣ ខែកញ្ញា)៖</u>

មូលបទនៃកិច្ចប្រជុំគឺ "ឈានឆ្ពោះទៅកសាងពិភពលោកដែលមានសុខភាពកាន់តែល្អប្រសើរ។ កិច្ចប្រជុំបានអនុម័តសេចក្តីថ្លែងការណ៍នយោបាយស្តីពីការធានារ៉ាប់រងសុខភាពជាសកល។ កម្ពុជាបានលើកអំពីបទពិសោធន៍របស់ខ្លួនក្នុងការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាព តាមរយៈការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០១៥ រួមជាមួយនឹងការពង្រីកវិសាលភាពនៃមូលនិធិជាតិសន្តិសុខសង្គម និងមូលនិធិសមធម៌សុខភាព។

<u>កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីចលនាមិនចូលបក្សសម្ព័ន្ធ (NAM) (ថ្ងៃទី២៦ ខែកញ្ញា)៖</u>

អង្គប្រជុំបានផ្តោតលើមូលបទ "ទ្រទ្រង់គោលការណ៍អធិបតេយ្យភាពនិងឯករាជ្យភាពនយោបាយដែលជាមធ្យោបាយក្នុងការរក្សាបាននូវសន្តិសុខនិងសន្តិភាពអន្តរជាតិ និងជំរុញទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋ" និងបានអនុម័តសេចក្តីថ្លែងការណ៍នយោបាយនៃទីក្រុងញូវយ៉ក។ កម្ពុជាបានចែករំលែកនូវបទពិសោធន៍ដែលទទួលបានពីប្រវត្តិសាស្ត្ររបស់ខ្លួន និងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃគោលការណ៍គោរពសមភាពអធិបតេយ្យភាព ឯករាជ្យភាព និងបូរណភាពដែនដី ព្រមទាំងការមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ដែលគោលការណ៍នេះដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់នីតិរដ្ឋនៅថ្នាក់ជាតិ និងអន្តរជាតិ។

កិច្ចប្រជុំពេញអង្គកម្រិតខ្ពស់ដើម្បីប្រារព្ធខួប និងលើកកម្ពស់ទិវាអន្តរជាតិសម្រាប់ការលុបបំបាត់ទាំងស្រុងអាវុធនុយក្លេអ៊ែរ (ថ្ងៃទី២៦ ខែកញ្ញា)៖

អង្គប្រជុំបានស្វាគមន៍ចំពោះការរំលឹក និងលើកកម្ពស់ទិវាអន្តរជាតិស្តីពីការលុបបំបាត់អាវុធនុយក្លេអ៊ែរទាំងស្រុង និងជំរុញឲ្យរដ្ឋទាំងអស់ ជាពិសេសប្រទេសដែលមានអាវុធនុយក្លេអ៊ែរ ចុះហត្ថលេខា និងផ្តល់សច្ចាប័នលើសន្ធិសញ្ញាហាមឃាត់គ្រប់ជ្រុងជ្រោយលើការសាកល្បងអាវុធនុយក្លេអ៊ែរ និងសន្ធិសញ្ញាហាមឃាត់អាវុធនុយក្លេអ៊ែរ ព្រមទាំងអនុវត្ត និងគោរពតាមកាតព្វកិច្ចដែលមានចែងក្នុងសន្ធិសញ្ញាទាំងនេះ និងសន្ធិសញ្ញារំសាយអាវុធនុយក្លេអ៊ែរពាក់ព័ន្ធផ្សេងទៀត។ កម្ពុជាបានស្នើឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា និងផ្តល់សច្ចាប័ន លើសន្ធិសញ្ញាហាមឃាត់គ្រប់ជ្រុងជ្រោយលើការសាកល្បងអាវុធនុយក្លេអ៊ែរ ។ ជាមួយអាស៊ាន កម្ពុជាបានរួមគ្នាបង្កើតតំបន់គ្មានអាវុធនុយក្លេអ៊ែរនៅអាស៊ីអាគ្នេយ៍ និងបន្តជំរុញប្រទេសសមាជិកអចិន្ត្រៃយ៍ទាំង ៥ នៃក្រុមប្រឹក្សាសន្តិសុខ អ.ស.ប ដើម្បីចុះហត្ថលេខាលើពិធីសារនៃសន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ។

កិច្ចប្រជុំប្រចាំឆ្នាំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសអភិវឌ្ឍន៍តិចតួច (LCDs)(ថ្ងៃទី២៦ ខែកញ្ញា)៖

កិច្ចប្រជុំបានអនុម័តសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ដែលសេចក្តីថ្លែងការណ៍នេះ ដើរតួនាទីជាផែនទីចង្អុលផ្លូវក្នុងការពន្លឿនការអភិវឌ្ឍនៅក្នុង LDCs និងការអនុវត្តផែនការសកម្មភាព Istanbul ។ កម្ពុជាបានជម្រាបជូនអង្គប្រជុំអំពីវឌ្ឍនភាពដែលខ្លួនសម្រេចបានលើការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការអនុវត្តគោលនយោបាយគ្រប់ជ្រុងជ្រោយដើម្បីកាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពអប់រំ និងសេដ្ឋកិច្ច លើកកម្ពស់សេវាសុខភាព និងសង្គម និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ី (ACD) (ថ្ងៃទី២៧ ខែកញ្ញា)៖

កិច្ចប្រជុំបានផ្តោតជាសំខាន់ទៅលើការត្រួតពិនិត្យឡើងវិញនូវសកម្មភាពឆ្នាំ២០១៩-២០២០ និងការវិវឌ្ឍចុងក្រោយនៃចក្ខុវិស័យ ACD ឆ្នាំ២០៣០ និងផែនការលម្អិត ឆ្នាំ២០១៧-២០២១។ កម្ពុជាបានគូសបញ្ជាក់សាជាថ្មីអំពីការសហការយ៉ាងជិតស្និទ្ធជាមួយសមាជិក ACD ដទៃទៀត ដើម្បីសម្រេចបាននូវចក្ខុវិស័យ ACD ឆ្នាំ២០៣០ ដែលស្របគ្នាជាមួយនឹងរបៀបវារៈឆ្នាំ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់ អ.ស.ប។

កិច្ចប្រជុំប្រចាំឆ្នាំ ថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រទេស G-77 + China លើកទី៤៣ (ថ្ងៃទី២៧ ខែកញ្ញា)៖

កិច្ចប្រជុំបានអនុម័តឯកសារ ២ គឺ ៖ ១)សេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការបរទេសក្រុមប្រទេស G-77 និងចិន ក្នុងឱកាសនៃនៃការប្រារព្ធខួបលើកទី៥៥ឆ្នាំ និង ២) សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រី។

កម្ពុជាបានជម្រាបជូនអង្គប្រជុំអំពីគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ខ្លួន និងគូសបញ្ជាក់ពីការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់ជីវិតមនុស្សរាប់លាននាក់។

**កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ (ថ្ងៃទី២៨ ខែកញ្ញា)៖**

កិច្ចប្រជុំបានពិភាក្សាពីភាពចាំបាច់ក្នុងការសម្រេចឲ្យបាននូវក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ សម្រាប់ឆ្នាំ២០១៩-២០២៣។ កិច្ចប្រជុំក៏បានពិចារណាលើលទ្ធភាពការរៀបចំជាទៀងទាត់នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ និងកិច្ចប្រជុំរវាងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន និងឯកអគ្គរាជទូតនៃប្រទេសសមាជិកក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រនៅហ្សាការតា។ កម្ពុជានឹងធ្វើជាប្រទេសសម្របសម្រួលសម្រាប់ភាគីអាស៊ាន នៅឆ្នាំ ២០២០ ខាងមុខនេះ។

**កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ (ថ្ងៃទី២៨ ខែកញ្ញា)៖**

កិច្ចប្រជុំបានពិភាក្សាលើការបង្កើតផែនទីបង្ហាញផ្លូវការបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក(២០២០ ២០២៥) រវាងចក្ខុវិស័យអាស៊ានឆ្នាំ២០២៥ និងរបៀបវារៈអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០ និងការដាក់ឲ្យដំណើរការនូវមជ្ឈមណ្ឌលអាស៊ានសម្រាប់កិច្ចសន្ទនា និងការសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅខែវិច្ឆិកា ឆ្នាំ២០១៩។ កិច្ចប្រជុំបានឯកភាពចំពោះសំណើរបស់អាល្លឺម៉ង់សុំចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍។ កិច្ចប្រជុំបានធ្វើការផ្លាស់ប្តូរយោបល់លើនិម្មាបនកម្មតំបន់ដែលកំពុងមានការវិវឌ្ឍ និងទំនាក់ទំនងជាមួយដៃគូសន្ទនាដែលផ្អែកលើមជ្ឈភាពអាស៊ាន។

**កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន និង ក្រុមប្រទេសសម្ព័ន្ធប៉ាស៊ីហ្វិក លើកទី៦ (ថ្ងៃទី២៨ ខែកញ្ញា)**

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំនេះ ជាមួយនឹងឯកឧត្តម តេអូដូរ៉ូ រីបេរ៉ា នូម៉ាន់ រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋស៊ីលី។ កិច្ចប្រជុំបានពិនិត្យមើលឡើងវិញនូវការអនុវត្តផែនការការងារអាស៊ាន និងក្រុមប្រទេសសម្ព័ន្ធប៉ាស៊ីហ្វិក (ឆ្នាំ២០១៧-២០១៩) នៅក្នុងវិស័យអាទិភាពទាំង ៤ រួមមាន៖ (១) កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច (២) ការអប់រំ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន (៣) វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និង (៤) ការអភិវឌ្ឍប្រកបដោយចីរភាព និងបានឯកភាពបន្តអនុវត្តផែនការការការងារនេះរហូតដល់ខែធ្នូ ឆ្នាំ២០២០។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ជាមួយអគ្គលេខាអ.ស.ប និងប្រធានកិច្ចប្រជុំមហាសន្និបាទអង្គការសហប្រជាជាតិលើកទី៧៤ (ថ្ងៃទី២៨ ខែកញ្ញា)៖</u>**

កិច្ចប្រជុំបានកត់សម្គាល់នូវវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដើម្បីអនុវត្តសេចក្តីប្រកាសរួមស្តីពីភាពជាដៃគូទូលំទូលាយរវាងអាស៊ាន និង អ.ស.ប (២០១៦-២០២០) និងសេចក្តីព្រាងផែនទីចង្អុលផ្លូវ (២០២០-២០២៥)។ កម្ពុជាបានលើកទឹកចិត្តឲ្យ អ.ស.ប ពិចារណាក្នុងការគាំទ្រមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន(ARMAC) ដើម្បីឲ្យមជ្ឈមណ្ឌលនេះមានលទ្ធភាពពង្រីកសមត្ថភាពរបស់ខ្លួនក្នុងការលើកកម្ពស់ការយល់ដឹងអំពីគ្រាប់មីន និងសំណល់គ្រាប់ផ្ទុះយុទ្ធភ័ណ្ឌ និងការជួយជនរងគ្រោះ ដើម្បីរួមចំណែកដល់សន្តិភាព និងសន្តិសុខ ក្នុងតំបន់និងពិភពលោកទាំងមូល។ ក្នុងប្រធានបទស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព កម្ពុជាក៏បានអំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌអាស៊ាន និង អ.ស.ប ដើម្បីប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងខ្វះគុណភាព ដែលជាការគំរាមកំហែងដ៏ធំមួយដល់សុខភាពសាធារណៈ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

**<u>កិច្ចប្រជុំទ្វេភាគី៖</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបទ្វេភាគីជាមួយនឹងឥស្សរជនដូចខាងក្រោម៖

១) លោកជំទាវ **ម៉ារីស ភែន** (Marise Payne) រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី

២) លោកជំទាវ **អេកាតេរីណា ហ្សាហារីវ៉ា** (Ekaterina Zaharieva) ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងជារដ្ឋមន្ត្រីការបរទេសប៊ុលហ្គារី

៣) ឯកឧត្តម **តូម៉ាស ផេទ្រីសេក** (Tomás Petříček)រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋឆេក

៤) ឯកឧត្តម **មីរ៉ូស្លាវ ឡាសឆាក** (Miroslav Lajčák) រដ្ឋមន្ត្រីការបរទេសស្លូវ៉ាគី

៥) ឯកឧត្តម **ជីងហ្គីស អៃដាបេកូវ** (Chingiz Aidarbekov) រដ្ឋមន្ត្រីការបរទេសគីរហ្គីស្ថាន

៦) ឯកឧត្តម **សឺហ្គេ ឡាវរ៉ូវ** (Sergey V. Lavrov) រដ្ឋមន្ត្រីការបរទេសរុស្ស៊ី

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានពិភាក្សាដោយផ្តោតលើការបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ការគាំទ្រគ្នាទៅវិញទៅមកក្នុងយន្តការពហុភាគី និងបានជម្រាបជូនសមភាគីអំពីវឌ្ឍនភាពសំខាន់ៗផ្នែកនយោបាយ និងសេដ្ឋកិច្ចរបស់កម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមស្តីពី "ការមិនដាក់សព្វាវុធលើលំហអាវកាស" ជាមួយឯកឧត្តម **សឺហ្គេ ឡាវរ៉ូវ** ផងដែរ៕

ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩